# សុន្ទរកថា
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៣៤ (កិច្ចប្រជុំពេញអង្គ)
## ក្រោមប្រធានបទ : «ជំរុញភាពជាដៃគូ ដើម្បីចីរភាព»
## រាជធានីបាងកក, ប្រទេសថៃ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៩

- ***ឯកឧត្តម ប្រាយុទ្ធ ចាន់អូចា ប្រធានអង្គប្រជុំ,***
- ***ព្រះចៅស៊ុលតង់, ឯកឧត្តម, លោកជំទាវថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ាន,***
- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ជាបឋម, ខ្ញុំសូមចូលរួមជាមួយថ្នាក់ដឹកនាំនៃប្រទេសអាស៊ាន, អបអរសាទរឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា** ដែលត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃសម្រាប់អាណត្តិថ្មី ក្រោយពីការបោះឆ្នោតថ្មីៗកន្លងទៅ និងក្នុងឋានៈឯកឧត្តមជាប្រធានអាស៊ានឆ្នាំ ២០១៩ ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការផ្តល់បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដល់រូបខ្ញុំ និងគណៈប្រតិភូ និងចំពោះការរៀបចំដ៏ល្អនៃកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៣៤ ក្រោមប្រធានបទ : «**ជំរុញភាពជាដៃគូ ដើម្បីចីរភាព**» ។

ឆ្នាំ ២០១៩ នេះ គឺជាខួប ២០ ឆ្នាំ ដែលកម្ពុជាបានចូលជាសមាជិកអាស៊ាន ។ កម្ពុជាពិតជាមានមោទនភាព ដែលបានចូលរួមជាសមាជិកនៃក្រុមគ្រួសារអាស៊ាន និងបានបំពេញកាតព្វកិច្ចជាសមាជិករបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីរួមចំណែករក្សាសន្តិភាព, សន្តិសុខ, ស្ថិរភាព, ការអភិវឌ្ឍ និងវិបុលភាពយូរអង្វែងនៅក្នុងសហគមន៍តំបន់ដ៏មានសារៈសំខាន់នេះ ។ ក្នុងស្មារតីបន្តជំរុញសម្រេចឱ្យបាននូវសហគមន៍អាស៊ានមួយប្រកបដោយថាមពល និងបរិយាបន្ន, ខ្ញុំសូមអនុញ្ញាតចូលរួមចែករំលែកនូវទស្សនៈមួយចំនួន ដូចខាងក្រោម ÷

**ទី១.** ឆ្នាំនេះ បើធៀបនឹងឆ្នាំមុនៗ, ទោះបីសភាពការណ៍នៅក្នុងតំបន់អាស៊ាន មានភាពល្អប្រសើរ, តែសភាពការណ៍ជាសកល, ទាំងនយោបាយ និងសេដ្ឋកិច្ច, កាន់តែមានភាពតានតឹង និងមិនប្រាកដប្រជា ។ ជម្លោះកាន់តែខ្លាំងនៅក្នុងសង្គ្រាមពាណិជ្ជកម្ម ក៏ដូចជាការកើនឡើងនៃការបោះពាក្យសំដី និងសកម្មភាពវិទ្ធង្សនា ដែលអាចនាំដល់ការធ្វើសង្គ្រាមនៅតំបន់មជ្ឈិមបូពា

បានគំរាមគំហែងដល់កំណើនសេដ្ឋកិច្ច, ទាំងក្នុងតំបន់ និងសកលលោក, និងអាចបំផ្លាញដល់វឌ្ឍនភាព និងសមិទ្ធផលជាច្រើនឆ្នាំនៃការធ្វើសមាហរណកម្ម និងសកលភាវូនីយកម្ម ដែលបានបង្កើតការងារ និងលើកកម្ពស់ជីវភាពប្រជាជន ។ ស្ថិតក្នុងបរិការណ៍នេះ, កម្ពុជាយល់ថា អាស៊ានត្រូវបន្តការពារ និងពង្រឹងនូវមជ្ឈភាពអាស៊ាន តាមរយៈការគោរពដោយម៉ឺងម៉ាត់នូវអធិបតេយ្យភាពរវាងរដ្ឋ និងរដ្ឋ, ការរក្សាឱ្យបាននូវឯកភាពអាស៊ាន, ការតម្កល់ផលប្រយោជន៍រួមជាធំ ក៏ដូចជាគោលការណ៍ជាមូលដ្ឋានផ្សេងៗទៀតរបស់អាស៊ាន ។ ជាមួយគ្នានេះដែរ, អាស៊ានគួរបន្តគាំទ្រយ៉ាងពេញទំហឹងនូវប្រព័ន្ធពាណិជ្ជកម្មសកល ដែលមានតម្លាភាព, ភាពបើកចំហរ និងផ្អែកលើគោលការណ៍ចម្បងរបស់អង្គការពាណិជ្ជកម្មពិភពលោក ក៏ដូចជាបន្តជំរុញកិច្ចសហប្រតិបត្តិការលើកិច្ចសម្រួលពាណិជ្ជកម្ម និងប្រយុទ្ធប្រឆាំងវិធានការគាំពានិយមគ្រប់រូបភាព ។

**ទី២.** កម្ពុជាសូមវាយតម្លៃខ្ពស់ និងគាំទ្រលើទិសដៅអាទិភាព ក៏ដូចជាគំនិតផ្តួចផ្តើមដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលថៃ សម្រាប់ការកសាងសហគមន៍អាស៊ាន, ដែលជាអាទិ៍សេចក្តីប្រកាសចក្ខុវិស័យរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីភាពជាដៃគូដើម្បីចីរភាព (Partnership for Sustainability) និងការបង្កើតបណ្តាញសមាគមនៃអាស៊ាន (Network of ASEAN Association) ដែលបានឆ្លុះបញ្ចាំងអំពីតម្រូវការជាក់ស្តែង, ការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការជំរុញភាពជាដៃគូ ទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ, និងការលើកកម្ពស់ការយល់ដឹងបន្ថែមទៀតពីអត្ថន័យរបស់អាស៊ាន (Sense of ASEAN) សំដៅបង្កើននូវកិច្ចសហប្រតិបត្តិការល្អប្រសើរ និងរួមចំណែកក្នុងនិម្មាបនកម្មតំបន់អាស៊ាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។

**ទី៣.** នៅក្នុងកិច្ចប្រជុំកំពូល RCEP លើកទី ២ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅសឹង្ហបុរី, ថ្នាក់ដឹកនាំបានណែនាំឱ្យរដ្ឋមន្ត្រីសេដ្ឋកិច្ចបញ្ចប់ការចរចាកិច្ចព្រមព្រៀង RCEP ក្នុងឆ្នាំ ២០១៩ នេះ ខណៈដែលប្រទេសថៃជាប្រធានអាស៊ាន ។ ហេតុនេះ យើងត្រូវតែរួមគ្នាពិនិត្យមើលលទ្ធផលសម្រេចបាន និងផ្តល់នូវឆន្ទៈនយោបាយដ៏មោះមុត សំដៅជំរុញឱ្យការចរចាត្រូវបានបញ្ចប់តាមការគ្រោងទុក ។ សង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាច និងការជាប់គាំងនៃអង្គឧទ្ធរណ៍ (Appellate Body) ព្រមទាំងការចុះខ្សោយនៃ WTO បានបន្ថយល្បឿននៃការអភិវឌ្ឍ និងការធ្វើពាណិជ្ជកម្មសកល ។ ដូច្នេះ, ការប្រកាសបញ្ចប់កិច្ចព្រមព្រៀង RCEP ក្នុងឆ្នាំ ២០១៩ នេះ ពិតជាមានសារៈសំខាន់ណាស់ចំពោះអាស៊ាន និងតំបន់អាស៊ីទាំងមូល សម្រាប់ទ្រទ្រង់ប្រព័ន្ធពាណិជ្ជកម្ម

សេរីគ្រប់ជ្រុងជ្រោយ និងផ្អែកតាមវិធានច្បាប់ត្រឹមត្រូវ ព្រមទាំងសម្រាប់ឆ្លើយតបទៅនឹងចរន្តគាំពារនិយម ។ ក្នុងស្មារតីនេះ, ខ្ញុំសូមស្នើថ្នាក់ដឹកនាំនៃបណ្តាប្រទេសជាសមាជិក RCEP ទាំងអស់ផ្តល់ការគាំទ្រផ្នែកនយោបាយបន្ថែមទៀត ដើម្បីឱ្យរដ្ឋមន្ត្រីសេដ្ឋកិច្ចរបស់យើង ដោះស្រាយបញ្ហាគន្លឹះៗ ដែលនៅសេសសល់ និងបញ្ចប់ការចរចាកិច្ចព្រមព្រៀង RCEP តាមការគ្រោងទុក ។ ក្រៅពី RCEP កម្ពុជាយល់ឃើញថា អាស៊ានក៏ត្រូវតែជំរុញការចរចារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន- អឺរ៉ុប និង អាស៊ាន- កាណាដា ឱ្យបានឆាប់ផងដែរ ។

**ទី៤.** កម្ពុជាវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពនៃការអនុវត្តផែនការការងារដំណាក់កាលទី ៣ នៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI Work Plan III) ដែលបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងសមាជិកអាស៊ាន ។ សម្រាប់ផែនការការងារឆ្នាំ ២០១៩ និងឆ្នាំទៅមុខទៀត, យើងគួរបន្តផ្តោតលើការអនុវត្តសេចក្តីសម្រេចទាំងឡាយកន្លងមកឱ្យបានកាន់តែសកម្ម និងខ្លាំងក្លាថែមទៀត ព្រមទាំងរួមគ្នាស្វែងរកនូវដំណោះស្រាយ ដែលមានប្រសិទ្ធភាព និងសមស្រប លើបញ្ហាប្រឈមដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្ត ។ កម្ពុជាស្វាគមន៍កិច្ចសហការរវាងអាស៊ាន និងអង្គការសហប្រជាជាតិ ដើម្បីសម្រេចនូវ «**គំនិតផ្តួចផ្តើមបំពេញបន្ថែមឱ្យគ្នា**» (Complementarities Initiative) រវាងរបៀបវារៈរបស់អង្គការសហប្រជាជាតិឆ្នាំ ២០៣០ និងចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ ២០២៥ ។ កម្ពុជាស្នើឱ្យមានការគាំទ្របន្ថែមទៀតពីអង្គការសហប្រជាជាតិ និងប្រទេសជាដៃគូខាងក្រៅរបស់អាស៊ានចំពោះការអនុវត្តផែនទីបង្ហាញផ្លូវនៃ «**គំនិតផ្តួចផ្តើមបំពេញបន្ថែមឱ្យគ្នា**» នេះ តាមរយៈយន្តការរបស់អាស៊ាន ។

**ទី៥.** កម្ពុជាផ្តល់សារៈសំខាន់ខ្ពស់ចំពោះផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ ២០២៥ ដែលប្រមូលផ្តុំដោយផែនការយុទ្ធសាស្ត្រសំខាន់ៗ សំដៅធ្វើឱ្យអាស៊ានក្លាយជាសហគមន៍មួយ ដែលមានភាពប្រកួតប្រជែងខ្ពស់ ព្រមទាំងមានភាពរឹងមាំ និងការផ្សារភ្ជាប់គ្នាយ៉ាងទូលំទូលាយ, ទាំងក្នុងតំបន់ និងក្រៅតំបន់ ។ ជាមួយនេះ កម្ពុជាសូមស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការសម្របសម្រួលការតភ្ជាប់អាស៊ាន, លេខាធិការដ្ឋានអាស៊ាន និងអង្គភាពនៃប្រទេសសមាជិកអាស៊ានទាំងអស់ ក្នុងការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ាន ។ កម្ពុជាយល់ឃើញថា ការអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ ២០២៥ និងការពង្រីកភាពជាដៃគូ សម្រាប់ការតភ្ជាប់, ទាំងផ្នែករូបវន្ត ស្ថាប័ន និងរវាងប្រជាជន, គឺជាការងារចាំបាច់ដែលអាស៊ានត្រូវបន្តខិតខំថែមទៀត ។

**ទី៦.** កម្ពុជាសូមថ្លែងអំណរគុណដល់ព្រះរាជាណាចក្រថៃ ដែលបានបញ្ចូលមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) ទៅក្នុងសេចក្តីប្រកាសទស្សនវិស័យរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីភាពជាដៃគូ ដើម្បីចីរភាព ។ នេះជាវឌ្ឍនភាពវិជ្ជមានមួយទៀតរបស់មជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) ក្នុងការទទួលការគាំទ្របន្ថែមពីអាស៊ាន ក៏ដូចជាពីបណ្តាប្រទេសដៃគូសន្ទនា ដើម្បីឱ្យមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) ដំណើរការបានពេញលេញស្របតាមផែនការការងារមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) ២០១៩-២០២១ ។ កម្ពុជាសូមលើកទឹកចិត្តមជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) ឱ្យធ្វើសកម្មភាពថ្នាក់តំបន់ ដើម្បីធានាថា សកម្មភាពរបស់មជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន (ARMAC) ពិតជាឆ្លើយតបប្រកបដោយប្រសិទ្ធភាព តាមគោលបំណងរបស់ខ្លួនដល់តំបន់អាស៊ាន ។ យើងក៏សូមលើកទឹកចិត្តឱ្យមានការគិតគូរចូលរួមគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស, តាមលទ្ធភាព, ពីបណ្តាប្រទេសមាជិកអាស៊ានដល់មជ្ឈមណ្ឌលនេះ ។

**ទី៧.** ពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមទីក្រុងឆ្លាតអាស៊ាន កម្ពុជាសូមវាយតម្លៃខ្ពស់ចំពោះវិធី-សាស្រ្តថ្មីៗ ដើម្បីទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាថ្មី ក្នុងការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជំរុញកំណើនសេដ្ឋកិច្ចប្រទេសសមាជិក ក៏ដូចជាកំណើនសេដ្ឋកិច្ចតំបន់អាស៊ានប្រកបដោយចីរភាព ។ ការអភិវឌ្ឍទីក្រុងនៅក្នុងប្រទេសសមាជិកអាស៊ាននីមួយៗ មានលក្ខណៈខុសៗគ្នា និងនៅមានគម្លាតនៅឡើយ ។ ហេតុនេះ, កម្ពុជាស្វាគមន៍ការយកចិត្តទុកដាក់ និងការចូលរួមក្នុងគំនិតផ្តួចផ្តើមបង្កើតបណ្តាញទីក្រុងឆ្លាតអាស៊ាននេះ ពីសំណាក់បណ្តាប្រទេសដៃគូសន្ទនា ដើម្បីជួយអភិវឌ្ឍផែនការទីក្រុងឆ្លាតសម្រាប់សមាជិកអាស៊ាននីមួយៗ តាមរយៈការចែករំលែកបទពិសោធន៍ល្អៗ, ជំនាញ និងបច្ចេកទេស ។

*សូមអរគុណ !*